ព័ត៌មានសង្ខេបអំពីគម្រោង
គ្រប់គ្រងធនធានទឹកចម្រុះ

*សកម្មភាពរួម ដំណោះស្រាយរួម*

# បញ្ហាគ្រប់គ្រងធនធាននេសាទឆ្លងដែនក្នុងទន្លេមេគង្គ និង ទន្លេសេកុង






ទន្លេមេគង្គ និងទន្លេសេកុងមានត្រីជាង ៨០០ ប្រភេទ ដែលផ្តល់នូវចំណូល និងស្បៀងអាហារដល់ប្រជាពលរដ្ឋដែលរស់នៅក្នុងខេត្តស្ទឹងត្រែង និងខេត្តក្រចេះ ក្នុងប្រទេសកម្ពុជា និងខេត្តចំប៉ាសាក់ និងខេត្តអាតាពឿ ក្នុងប្រទេសឡាវ ដែលជាខេត្តជាប់ព្រំដែនជាមួយគ្នា។ ប៉ុន្តែទន្លេទាំង ២ នេះប្រឈមនឹងការគម្រាមកំហែងជាច្រើនដូចជា ការនេសាទដែលពុំមាននិរន្តភាព ការកើនឡើងយ៉ាងឆាប់រហ័សនៃការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និង ការប្រែប្រួលអាកាសធាតុ ដែលធ្វើឲ្យខូចខាតដល់ដែនជំរកត្រី។

ដើម្បីដោះស្រាយបញ្ហានេះ និង ដើម្បីការពារបរិស្ថាន និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ប្រទេសកម្ពុជា និងប្រទេសឡាវ បានខិតខំប្រឹងប្រែងកែលម្អការគ្រប់គ្រងធនធាននេសាទ ក្នុងខេត្តដែលជាប់ភូមិផងរបងជាមួយគ្នាទាំងនេះ តាមរយៈគម្រោងទ្វេភាគីមួយ ដែលទទួលបានការគាំទ្រពីគណៈកម្មការទន្លេមេគង្គ (MRC)។

ប្រទេសទាំង ២ បានធ្វើការសិក្សា និងបានកំណត់នូវបញ្ហាជាអាទិភាពចំនួន ៧ ពាក់ព័ន្ធនឹងការគ្រប់គ្រងធនធាននេសាទឆ្លងដែន ក្នុងអាងទន្លេមេគង្គ និងទន្លេសេកុងនេះ ដោយបានធ្វើការពិគ្រោះយោបល់ជាមួយតួអង្គពាក់ព័ន្ធនានា ហើយក៏បានចុះធ្វើការអង្កេតនៅតាមមូលដ្ឋានផ្ទាល់ជាច្រើនផងដែរ។

## គម្រោងគ្រប់គ្រងធនធាននេសាទក្នុងទន្លេមេគង្គ និង សេកុង

គម្រោងគ្រប់គ្រងធនធាននេសាទក្នុងទន្លេមេគង្គនិងទន្លេសាកុង គឺជាគំនិតផ្តួចផ្តើមមួយ ក្នុងចំណោមគំនិតផ្តួចផ្តើមទ្វេភាគីចំនួន ៥ របស់គណៈកម្មការទន្លេមេគង្គ ដើម្បីឆ្លើយតបទៅនឹងបញ្ហាការរៀបចំផែនការ និងគ្រប់គ្រងធនធានទឹកឆ្លងដែនតាមរយៈកិច្ចសហប្រតិបត្តិការ។

ដោយទទួលបានមូលនិធិពីធនាគារពិភពលោក គម្រោងនេះជម្រុញឲ្យមានការសម្របសម្រួលការអនុវត្តន៍សកម្មភាព ស្របតាមគោលការណ៍នៃការគ្រប់គ្រងធនធានទឹកចម្រុះ (IWRM) ដែលជាទស្សនទានសកល មានគោលបំណងធ្វើឲ្យមានតុល្យភាពរវាងតម្រូវការអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ច និង ការការពារបរិស្ថានក្នុងសហគមន៍តាមដងទន្លេ។ គម្រោងនេះ នឹងបំពាក់បំប៉នប្រទេសទាំង ២ នូវសមត្ថភាព និងឧបករណ៍ ដើម្បីបន្តអនុវត្តសកម្មភាពរួមគ្នាក្រោយគម្រោងនេះបញ្ចប់។

# បញ្ហាគ្រប់គ្រងធនធាននេសាទឆ្លងដែនជាអាទិភាព

ព័ត៌មានលំអិតអំពីបញ្ហាទាំង ៧ ត្រូវបានចងក្រងទុកនៅក្នុងឯកសារបច្ចេកទេសរួមគ្នាមួយ ដែលមានចំណងជើងថា *ការគ្រប់គ្រងធនធាននេសាទឆ្លងដែនក្នុងទន្លេមេគង្គ និង ទន្លេសេកុងនៃប្រទេសកម្ពុជា និងប្រទេសឡាវ* ដែលត្រូវបានបោះពុម្ពផ្សាយនៅខែ កញ្ញា ឆ្នាំ ២០១៧។







១ **ការនេសាទលើសលុប៖** ខណៈពេលដែលកំណើនប្រជាជនធ្វើឲ្យមានតម្រូវការត្រីសម្រាប់ធ្វើជាអាហារ និង រកប្រាក់ចំណូលកាន់តែច្រើន អ្នកនេសាទត្រូវរងសម្ពាធធ្វើការនេសាទឲ្យបានកាន់តែច្រើនលើសលុបផងដែរ។ បច្ចេកវិទ្យា និង ឧបករណ៍នេសាទថ្មីៗបានលើកទឹកចិត្តឲ្យពួកគេចាប់ត្រីក្នុងបរិមាណកាន់តែច្រើន ហើយជាលទ្ធផល ការប្រើប្រាស់ឧបករណ៍នេសាទ ដែលអាចចាប់ត្រីបានច្រើនបែបនេះ បានបង្កើនសមត្ថភាពរបស់អ្នកនេសាទទាំងនោះ ក្នុងការប្រកួតប្រជែងកាន់តែច្រើនជាងមុន និង អាចបំពេញទៅតាមតម្រូវការទីផ្សារកាន់តែច្រើនជាងមុនផងដែរ។ ជាលទ្ធផល ស្តុកត្រីត្រូវរងភាពហិនហោចទាំងពូជនិងទំហំត្រី។ ការផ្តល់នូវប្រភពចំណូលផ្សេងទៀត (ដូចជាវារីវប្បកម្ម ការចិញ្ចឹមសត្វ និង ទេសចរណ៍ធម្មជាតិ ជាដើម) អាចជួយឲ្យអ្នកនេសាទទ្រទ្រង់ជីវភាពរស់នៅរបស់គ្រួសារពួកគេ តាមរបៀបផ្សេង ដែលអាចនាំឲ្យមានការកាត់បន្ថយការនេសាទលើសលុបបែបនេះ។

២ **ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់៖** អ្នកនេសាទជាច្រើនក្នុងប្រទេសទាំង ២ ប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ ដូចជា មងដែលមានក្រឡាតូចល្អិត រំសេវផ្ទុះ និង ឧបករណ៍ឆក់ជាដើម។ ការប្រើប្រាស់ឧបករណ៍ទាំងនេះ ធ្វើឲ្យចំនួន និង ប្រភេទត្រី មានការថយចុះ ហើយក៏បង្កផលប៉ះពាល់ដល់សុវត្ថិភាពរបស់ប្រជាពលរដ្ឋ ដែលរស់នៅតាមមូលដ្ឋានផងដែរ។ ការពង្រឹងការអនុវត្តច្បាប់ប្រកបដោយប្រសិទ្ធភាព និង ការធ្វើឲ្យប្រាក់ចំណូលបានមកពីច្រើនប្រភព នឹងអាចជួយដោះស្រាយបញ្ហានេះបាន។

៣ **ការរិចរិលដែនជំរកត្រី៖** ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធទឹក បង្កការគម្រាមកំហែងដល់ដែនជំរកត្រី ក៏ដូចជាដល់សន្តិសុខស្បៀង និង សកម្មភាពចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋនៅក្នុងសហគមន៍តាមដងទន្លេ។ ការកាប់ឈើ ការដាក់រំសេវផ្ទុះនិងការបូមខ្សាច់យ៉ាងគំហុក និង ការសាងសង់ទំនប់ បានធ្វើឲ្យមានការបាត់បង់ព្រៃឈើ ការច្រោះដីការបំពុលដោយសារសារធាតុប៉ារត និង មុខសញ្ញាគ្រោះថ្នាក់បរិស្ថានដទៃទៀត ដែលនាំឲ្យចំនួននិងផលិតកម្មត្រីមានការថយចុះ។ ចាំបាច់ត្រូវតែមានវិធានការដើម្បីកាត់បន្ថយផលប៉ះពាល់ទាំងនេះ។

៤ **ការប្រែប្រួលផលចាប់របស់ត្រី៖** ដោយសារសកម្មភាពអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធការនេសាទពុំមាននិរន្តភាព និង ការប្រែប្រួលអាកាសធាតុ អ្នកនេសាទនៅក្នុងប្រទេសកម្ពុជា និង ឡាវ បានរាយការណ៍ពីការថយចុះនៃផលចាប់របស់ពួកគេ ហើយបច្ចុប្បន្ននេះត្រីភាគច្រើនដែលពួកគេចាប់បាន គឺជាត្រីដែលមានទំហំតូច។ ការនេះ អាចបង្កផលប៉ះពាល់ជាអវិជ្ជមានដល់ប្រជាពលរដ្ឋក្រីក្រ។ រដ្ឋាភិបាលនៃប្រទេសទាំង ២ ចាំបាច់ត្រូវរៀបចំនូវវិធានការការពារដែនជំរកត្រី ដើម្បីកាត់បន្ថយការប្រែប្រួលនៃផលចាប់នេះ។

**ប្រទេស៖**
កម្ពុជា និងឡាវ

**ថវិកា៖**
៥៣៥.២០០ ដុល្លារ

**រយៈពេល៖**
ពីខែកក្កដា ឆ្នាំ២០១៤ ដល់ ខែមិនា ឆ្នាំ២០១៨

៥ **យន្តការគ្រប់គ្រងធនធាននេសាទឆ្លងដែន៖** បើទោះបីជាប្រទេសកម្ពុជា និង ប្រទេសឡាវ បានបង្កើតយន្តការចំរុះមួយក្នុងឆ្នាំ ២០០៦ ដើម្បីឆ្លើយតបចំពោះបញ្ហានេសាទលើសលុប និង បញ្ហាដទៃទៀត ដែលខេត្តជាប់ព្រំដែនជាមួយគ្នាទាំងនេះជួបប្រទះ យ៉ាងណាក៏ដោយ យន្តការនេះបានរលាយបាត់ទៅវិញ ដោយសារថវិកាមានកម្រិត និង ខ្វះការចូលរួមពីអាជ្ញាធរខេត្ត។ ចាំបាច់ត្រូវមានការបង្កើតយន្តការសហការគ្នាថ្មីមួយ ដើម្បីលើកកម្ពស់ការទំនាក់ទំនងនៅថ្នាក់ខេត្ត ដោយមានការគាំទ្រពីថ្នាក់ក្រសួង។

៦ **ការចែករំលែកទិន្នន័យ និង ព័ត៌មានអំពីធនធាននេសាទនៅមានកម្រិត៖** ចំណេះដឹងអំពីប្រភេទត្រី និងការយល់ដឹងអំពីពូជត្រី ដែលធ្វើដំណើររយៈចម្ងាយឆ្ងាយ និងព័ត៌មានអំពីការបរិភោគត្រី និងវារីសត្វដទៃទៀត នៅមានកម្រិតទាប។ ប្រទេសទាំង២ ចាំបាច់ត្រូវប្រមូលទិន្នន័យធនធាននេសាទ និងចែករំលែកព័ត៌មាននេះ ជាមួយអ្នកពាក់ព័ន្ធ ដែលកំពុងធ្វើការងារក្នុងវិស័យនេះ ដើម្បីបង្កើនការយល់ដឹងឲ្យមានការគ្រប់គ្រងកាន់តែល្អប្រសើរជាងមុន។

៧ **ធនធាន និង សមត្ថភាពគ្រប់គ្រងធនធាននេសាទ៖** រដ្ឋាភិបាលរបស់ប្រទេសទាំង២ ខ្វះមន្ត្រីដែលមានសមត្ថភាពគ្រប់គ្រាន់ខាងវិទ្យាសាស្ត្រ និង ការគ្រប់គ្រងធនធាននេសាទ ជាពិសេសនៅថ្នាក់ខេត្តនិងថ្នាក់ស្រុក។ ការនេះ តម្រូវឲ្យមានការផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីទាំងនេះ អំពីការរៀបចំផែនការគ្រប់គ្រងធនធាននេសាទ ការពិនិត្យតាមដានផលចាប់ត្រី ការគ្រប់គ្រងគម្រោង និង ការបណ្តុះបណ្តាលនៅនឹងការងារផ្ទាល់ អំពីរបៀបចុះធ្វើការស្រាវជ្រាវនិងទំនាក់ទំនង ដើម្បីបន្តការគាំទ្រដល់ការបន្តកិច្ចពិគ្រោះយោបល់ ដែលធ្វើឡើងដោយមន្ត្រីទាំងនេះ។







## សកម្មភាពទ្វេភាគី ៖

ប្រទេសកម្ពុជា និងប្រទេសឡាវ បានឯកភាពគ្នាចាត់វិធានការជាជំហានៗជាច្រើន ដើម្បីឆ្លើយតបទៅនឹងបញ្ហាឆ្លងដែនជាអាទិភាពរបស់ខ្លួន តាមរយៈគម្រោងទ្វេភាគីនេះ៖

១. បង្កើត **កម្មវិធីពិនិត្យតាមដានធនធាននេសាទរួមគ្នា** ដើម្បីពិនិត្យតាមដានប្រភេទត្រីស ដែលធ្វើដំណើររយៈចម្ងាយឆ្ងាយ ដែលរកឃើញនៅតំបន់ព្រំដែន ដើម្បីស្វែងយល់ពីស្ថានភាព និងនិន្នាការ នៃការចាប់ពូជត្រីទាំងនេះ និងធ្វើការវាយតម្លៃពីឥទ្ធិពលនៃការគ្រប់គ្រងទឹក ឲ្យកាន់តែមានប្រសិទ្ធភាពបន្ថែមទៀត។

២. បង្កើត **យន្តការសម្របសម្រួលចំរុះ** នៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន រវាងប្រទេសកម្ពុជា និងប្រទេសឡាវ ដើម្បីកែលម្អការចែករំលែកព័ត៌មានអំពីទិន្នន័យធនធាននេសាទ និង សម្របសម្រួលកិច្ចខិតខំប្រឹងប្រែង ក្នុងការឆ្លើយតបចំពោះបញ្ហាប្រឈមជាអាទិភាពមួយចំនួន។

៣. រៀបចំ **ផែនការសកម្មភាពរួមគ្នា** ដើម្បីអនុវត្តយន្តការសម្របសម្រួលនេះ។

បន្ទាប់ពីគម្រោងនេះត្រូវបានបញ្ចប់ ប្រទេសទាំង២នឹងត្រូវបន្តកិច្ចពិគ្រោះយោបល់ទ្វេភាគី ដើម្បីបង្កើតនូវ **ស្ថាប័នគ្រប់គ្រងធនធាននេសាទចំរុះមួយ** ដែលមានតួនាទីអនុវត្តផែនការសកម្មភាពនេះ។ កិច្ចខិតខំប្រឹងប្រែងរយៈពេលយូរទាំងនេះ នឹងជួយលើកកម្ពស់ជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន ក៏ដូចជាបង្កើនសន្តិសុខស្បៀងរបស់ពួកគាត់ផងដែរ។


**លេខាធិការដ្ឋាន
គណៈកម្មការទន្លេមេគង្គ**

អាគារលេខ ១៨៤ ផ្លូវ ហ្វាង្ហម
ប្រអប់សំបុត្រលេខ ៦១០១
ទីក្រុងវៀងច័ន្ទ ប្រទេសឡាវ

ទូរស័ព្ទ: +៨៥៦ ២១ ២៦៣២៦៣

ទូរសារ: +៨៥៦ ២១ ២៦៣៣៦៤

អ៊ីម៉ែល: mrcs@mrcmekong.org

MEKONG RIVER COMMISSION
MRC
FOR SUSTAINABLE DEVELOPMENT

© រក្សាសិទ្ធិគ្រប់យ៉ាងដោយគណៈកម្មការទន្លេមេគង្គ ឆ្នាំ២០១៧